ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

| |
|---|
| តុលាការខេត្ត |
| សៀមរាប_ឧត្តរមានជ័យ |
| <u>សាលក្រម</u> |
| លេខ ៨៣ ខ ចុះថ្ងៃទី ២៨ |
| ខែ មិថុនា ឆ្នាំ ២០០៦ |
| <u>សំណុំរឿងរដ្ឋប្បវេណី</u> |
| លេខ ១៤៣ ចុះថ្ងៃទី ០៣ |
| ខែ ឧសភា ឆ្នាំ ២០០៦ |

## នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការខេត្តសៀមរាប_ឧត្តរមានជ័យ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ នាថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០៦ ដោយមានសមាសភាព :

<u>**ចៅក្រមជំនុំជំរះ**</u>

លោក [redacted] ប្រធានតុលាការខេត្ត

<u>**តំណាងអយ្យការ**</u>

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្ត

<u>**ក្រឡាបញ្ជីសវនាការ**</u>

លោកស្រី [redacted] ក្រឡាបញ្ជីតុលាការខេត្ត

ដើម្បីជំនុំជំរះរឿងក្តីរដ្ឋប្បវេណីលេខ ១៤៣ ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៦ ដែលមានកម្មវត្ថុបណ្តឹង : **<u>ប្តឹងសុំលែងលះប្តី</u>, ប្តឹងសុំសិទ្ធិគ្រប់គ្រងកូន, ប្តឹងសុំប្រាក់អាហារកិច្ចចិញ្ចឹមកូន ១០.០០០ដុល្លា (មួយម៉ឺនដុល្លាសហរដ្ឋអាមេរិក), ប្តឹងសុំបែងចែកទ្រព្យសម្បត្តិរួម** ។

រវាងដើមចោទឈ្មោះ ម ត អាយុ ៣៤ឆ្នាំ ជាតិខ្មែរ របររកស៊ីនៅផ្ទះ ទីលំនៅ ភូមិស្ទឹង ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប ។ ឪពុកឈ្មោះ ស ត (រ) ម្តាយឈ្មោះ ត ៩ (រ) ប្តីឈ្មោះ ម សធ មានកូន ០៣នាក់ ។

និង ចុងចម្លើយឈ្មោះ ម សធ ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែ ទីលំនៅភូមិស្ទឹង ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប ។ ឪពុកឈ្មោះ ម ស (ស) ម្តាយឈ្មោះ ម ឈ (រ) ប្រពន្ធឈ្មោះ ម ត មានកូន ០៣នាក់ ។

<u>**ដំណើររឿងមានដូចតទៅ**</u> :

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៦ ដើមចោទឈ្មោះ ម ត បានប្តឹងសុំលែងលះចុងចម្លើយឈ្មោះ ម សធ ដោយសំអាងហេតុថា បានរៀបការត្រឹមត្រូវតាមច្បាប់ជាមួយចុងចម្លើយតាំងពីឆ្នាំ ១៩៩៥ រហូតមកដល់ពេលនេះមានកូន ០៣នាក់ ។ ប្តីរបស់ខ្លួនបានវាយធ្វើបាប យោរយៅដល់ប្រពន្ធកូនចុះចេញពីផ្ទះ ០៩ខែពុំដែលបានជួយទំនុកបំរុងគ្រួសារទេ និង ទៅមានស្រីថ្មីទៀត ។ ធ្វើអោយខ្លួន

សាលក្រមនេះចូលជាស្ថាពរចាប់ពីថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៦
ដោយពុំមានភាគីណាមួយចូលមកប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។
សៀមរាប,ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៦
**ក្រឡាបញ្ជី**
**ហត្ថលេខា និង ត្រា**
[redacted]

CamScanner

មិនអាចស៊ូទ្រាំរស់នៅជាប្តី ប្រពន្ធតទៅទៀតបានឡើយ ។

## នារពេលសទនាការ

ដើមចោទឈ្មោះ ម ត បានឆ្លើយថា ខ្លួនប្តឹងសុំលែងលះចុងចម្លើយដោយមូលហេតុខ្លួនបានរៀបការត្រឹមត្រូវតាមច្បាប់តាំងពីឆ្នាំ ១៩៩៥ រហូតមកដល់ពេលនេះមានកូន ០៣នាក់ ។ តែការរស់នៅមិនចុះសំរុងនឹងគ្នាសោះ ប្តីរបស់ខ្លួនបានវាយធ្វើបាបឃោរឃៅដល់ខ្លួន និង កូន ហើយចុះចេញពីផ្ទះរយៈពេល ០៩ខែពុំដែលជួយទំនុកបំរុងគ្រួសារទេ និង ទៅមានស្រីថ្មីទៀត ធ្វើអោយខ្លួនពុំអាចស៊ូទ្រាំរស់នៅជាប្តីប្រពន្ធតទៅទៀតបានឡើយ ។

ចំពោះកូន ០៣នាក់ គឺកូនទី១ ឈ្មោះ ស សធ ភេទប្រុស អាយុ ១០ឆ្នាំ. កូនទី២ ឈ្មោះ ស បធ ភេទប្រុស អាយុ ០៩ឆ្នាំ និង កូនទី៣ ឈ្មោះ ស បថ ភេទប្រុស អាយុ ០៧ឆ្នាំខ្លួនសុំសិទ្ធិគ្រប់គ្រង ហើយទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូនផ្តាច់ចំនួន ១.០០០ដុល្លា ( មួយពាន់ដុល្លាអាមេរិក) តាមសំណូមពររបស់ប្តីថា អោយនោះទាំងស្រុង ។

រីឯទ្រព្យសម្បត្តិរួមមាន :

ទី១ : ដីមួយកន្លែង ស្ថិតនៅភូមិថ្នល់លោក ឃុំស្ពានត្នោត ស្រុកជីក្រែង ខេត្តសៀមរាប មានព្រំប្រទល់ខាងជើងទល់ឈ្មោះ ខុធ ខាងត្បូងទល់ឈ្មោះ ម៉ុត ខាងកើតទល់ឈ្មោះ ម៉ុត និង ខាងលិចទល់ផ្លូវ មានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលមានលេខ ១១០/២០០៥ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៥ របស់លោកមេឃុំស្ពានត្នោត ។

ទី២ : ដីមួយកន្លែងស្ថិតនៅភូមិត្រាច ឃុំបល្ល័ង្ក ស្រុកប្រាសាទបាគង ខេត្តសៀមរាប មានព្រំប្រទល់ខាងជើងទល់ផ្លូវរទេះ ខាងត្បូងទល់ឈ្មោះ ម ម ខាងកើតទល់ផ្លូវលំ និង ខាងលិចទល់ឈ្មោះ ខ ត មានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤ ដែលមានលេខ ៧០៤ ឃបល ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៤ របស់លោកមេឃុំបល្ល័ង្ក ។

ទី៣ : ម៉ូតូមួយគ្រឿងម៉ាក VIVA ពណ៌ក្រហមសេរី ២០០៦ ហាងអ៊ុតសក់មួយកន្លែង ស្ថិតនៅភូមិទ្រាំង ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ជង្រុកស្រូវមួយស្ថិតនៅភូមិថ្នល់លោក ឃុំស្ពានត្នោត ស្រុកជីក្រែង ខេត្តសៀមរាប ខ្លួនសុខចិត្តប្រគល់អោយទៅប្តីឈ្មោះ ម សធ គ្រប់គ្រងជាកម្មសិទ្ធិចុះ ។

ទី៤ : ដីមួយកន្លែងស្ថិតនៅភូមិចំរេះ ឃុំស្ពានត្នោត ស្រុកជីក្រែង ខេត្តសៀមរាប មានព្រំប្រទល់ខាងជើងទល់ផ្លូវជាតិលេខ ៦អា ខាងត្បូងទល់ផ្លូវលំ ខាងកើតទល់ឈ្មោះ ម៉ុត និង ខាងលិចទល់ឈ្មោះ តែ មានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៤ ដែលមានលេខ ៧៥/២០០៤ ចុះនៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៤ របស់លោកមេឃុំបល្ល័ង្ក ។

ទី៥ : ដីមួយកន្លែងស្ថិតនៅភូមិគីឡូតាឈឹម ឃុំគោកធ្លកក្រោម ស្រុកជីក្រែង ខេត្តសៀមរាប មានព្រំប្រទល់ខាងជើងទល់ឈ្មោះ ច ខ ខាងត្បូងទល់ផ្លូវជាតិលេខ ៦អា ខាងកើតទល់ឈ្មោះ ស ច និង ខាងលិចទល់ឈ្មោះ ស ច មានលិខិតបញ្ជាក់របស់លោកមេឃុំគោកធ្លកក្រោម លេខ ៩៦/២០០៤ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៤ ។

ទី៦ : ដីមួយកន្លែងស្ថិតនៅភូមិគីឡូតាឈឹម ឃុំគោកធ្លកក្រោម ស្រុកជីក្រែង ខេត្តសៀមរាប មានព្រំប្រទល់ខាងជើងទល់ឈ្មោះ ស ស ខាងត្បូងទល់ផ្លូវជាតិលេខ ៦អា ខាងកើតទល់ឈ្មោះ គ គ ខាងលិចទល់ឈ្មោះ ស ស មានលិខិតបញ្ជាក់របស់លោកមេឃុំគោកធ្លកក្រោមលេខ ៩៥/២០០៤ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៤ ។

CamScanner

ទី៧ : គោញីមួយក្បាល និង ទូបេង ០២គ្រឿង. គ្រែបេង ០១គ្រឿ។. ខ្ទះសំរាប់អង្គុយលេង. តុបេង ០១. កៅអីបេង ០៩. ជង្រុកស្រូវមួយ និង ផ្ទះបាយមួយ និង សំភារៈផ្សេង១ទៀតនៅលើដីរបស់ម្តាយខ្លួននោះ ខ្លួនសុំសិទ្ធិគ្រប់គ្រងជាកម្មសិទ្ធិតាមសំណូមពររបស់ប្តីទាំងស្រុង ។

ចំណែកឯដីមួយកន្លែងស្ថិតនៅផ្លូវទៅភ្នំបូក ស្ថិតនៅភូមិលលៃ ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប មានព្រំប្រទល់ខាងជើងទល់ឈ្មោះ ម ឥ ខាងត្បូងទល់ឈ្មោះ ឣ ខាងកើតទល់ស្ទឹង និង ខាងលិចទល់ផ្លូវមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៤ ដែលមានលេខ ៥១៨/២០០៤ឃបគ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤ របស់លោកមេឃុំបាគង ជាទ្រព្យផ្ទាល់ខ្លួនរបស់ខ្លួនមានមុនបានឈ្មោះ ម សឍ ជាប្តីនោះខ្លួនសុំសិទ្ធិគ្រប់គ្រងថា ទ្រព្យផ្ទាល់របស់ខ្លួនផ្សេងពីនេះខ្លួនមិនទទួមទារសើរើបន្តទៅទៀតឡើយ ។

ចំណែកឯបំណុលរួមមានឈ្មោះ ថវត ជំពាក់ស្រូវចំនួន ៤០ថាំង. ឈ្មោះ ន សខ ជំពាក់ប្រាក់ចំនួន ១០០ដុល្លាអាមេរិក ខ្លួនសុខចិត្តចែកបំណុលនេះពាក់កណ្តាលម្នាក់ស្មើគ្នា ។

ប្តីរបស់ខ្លួនសន្យាថា អោយមាសចំនួន ០១ជី ០៥ហ៊ុន នៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៦ ជាចំណែកពាក់កណ្តាលថ្លៃបញ្ចាំដីស្រែមកខ្លួននោះ ខ្លួនសុខចិត្តទទួលយកទាំងស្រុង ដើម្បីបញ្ចប់រឿងក្តីនេះ ។

ចំពោះដីទិញ-លក់ ក្នុងក្រុមហ៊ុនមានគ្នា ០៩នាក់ គឺមានឈ្មោះ ម ឥ ០១. ឈ្មោះ ស ឡ ០១. ឈ្មោះ គ ត ០១. ឈ្មោះ ត ឥ ០១. ឈ្មោះ ថ ឥ ០១. ឈ្មោះ ឡ បអ ០១. ពេច្ឆាះ ថុន ០១ និង ខ្លួន និង ប្តីខ្លួន ០១ នោះ នៅពេលដោះស្រាយលក់ដីនេះបានប្រាក់ខ្លួនយល់ព្រមទទួលយកចំណែកពាក់កណ្តាល តាមសំណូមពររបស់ប្តីទាំងស្រុង ។

ចុងចម្លើយឈ្មោះ ម សឍ បានឆ្លើយថា ខ្លួនក៏យល់ព្រមលែងលះដើមចោទដែរ ដោយមូលហេតុបានរៀបការត្រឹមត្រូវតាមច្បាប់តាំងពីឆ្នាំ ១៩៩៥ រហូតមកដល់ពេលនេះមានកូន ០៣នាក់ ។ ថា ការរស់នៅមិនចុះសំរុងនឹងគ្នាទេ ព្រោះប្រពន្ធលក់ទ្រព្យសម្បត្តិពុំដែលពិគ្រោះជាមួយខ្លួនទេ ។ នៅពេលមានទំនាស់បន្តិចបន្តួចខ្លួនគ្រាន់តែប្រវាយប្រតប់គ្នាប៉ុណ្ណោះ ពុំដែលវាយធ្ងន់ធ្ងរឡើយ ។

ចំពោះកូន ០៣នាក់ គឺកូនទី១ ឈ្មោះ ស សឍ ភេទប្រុស អាយុ ១០ឆ្នាំ. កូនទី២ ឈ្មោះ ស មឍ ភេទប្រុស អាយុ ០៩ឆ្នាំ និង កូនទី៣ ឈ្មោះ ស មថ អាយុ ០៧ឆ្នាំ ខ្លួនសុខចិត្តប្រគល់អោយទៅប្រពន្ធគ្រប់គ្រងចុះហើយខ្លួនជួយផ្តល់ប្រាក់អាហារកិច្ចចិញ្ចឹមកូនផ្តាច់ចំនួន ១.០០០ដុល្លា ( មួយពាន់ដុល្លាអាមេរិក) ។

រីឯទ្រព្យសម្បត្តិរួមមាន :

ទី១ : ដីមួយកន្លែងស្ថិតនៅភូមិថ្នល់លោក ឃុំស្ពានត្នោត ស្រុកជីក្រែង ខេត្តសៀមរាប មានព្រំប្រទល់ខាងជើងទល់ឈ្មោះ ខុឍ ខាងត្បូងទល់ឈ្មោះ ហ៊ុត ខាងកើតទល់ឈ្មោះ ហ៊ុត និង ខាងលិចទល់ផ្លូវមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលមានលេខ ១១០/២០០៥ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៥ របស់លោកមេឃុំស្ពានត្នោត ។

ទី២ : ដីមួយកន្លែងស្ថិតនៅភូមិត្រាច ឃុំបល្ល័ង្ក ស្រុកប្រាសាទបាគង ខេត្តសៀមរាប មានព្រំប្រទល់ខាងជើងទល់ផ្លូវរទេះ ខាងត្បូងទល់ឈ្មោះ ម ម ខាងកើតទល់ផ្លូវលំ និង ខាងលិចទល់ឈ្មោះ ទ ត មានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤ ដែលមានលេខ ៧០៤ ឃបល ចុះនៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៤ របស់លោកមេឃុំបល្ល័ង្ក ។

ទី៣ : ម៉ូតូមួយគ្រឿងម៉ាក VIVA ពណ៌ក្រហម ស៊េរី ២០០៦ ហាងអ៊ុតសក់មួយកន្លែង ស្ថិតនៅ ភូមិទ្រាំង ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ជង្រុកស្រូវមួយស្ថិតនៅថ្នល់លោក ឃុំស្ពានត្នោត ស្រុកជីក្រែង ខេត្តសៀមរាប

CamScanner

ខ្លួនសុំសិទ្ធិគ្រប់គ្រងជាកម្មសិទ្ធិ ។

ទី៤ : ដីមួយកន្លែងស្ថិតនៅភូមិចំរេះ ឃុំស្ពានត្នោត ស្រុកជីក្រែង ខេត្តសៀមរាប មានព្រំប្រទល់ខាងជើងទល់ផ្លូវជាតិលេខ ៦អា ខាងត្បូងទល់ផ្លូវលំ ខាងកើតទល់ឈ្មោះ ថ្មឺត និង ខាងលិចទល់ឈ្មោះ តែ មានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៤ ដែលមានលេខ ៧៥/២០០៤ ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៤ របស់លោកមេឃុំបល្ល័ង្គ ។

ទី៥ : ដីមួយកន្លែងស្ថិតនៅភូមិគីឡូតាឈឹម ឃុំគោកធ្លកក្រោម ស្រុកជីក្រែង ខេត្តសៀមរាប មានព្រំប្រទល់ខាងជើងទល់ឈ្មោះ ស ស ខាងត្បូងទល់ផ្លូវជាតិលេខ ៦អា ខាងកើតទល់ឈ្មោះ ស ច និង ខាងលិចទល់ឈ្មោះ ស ច មានលិខិតបញ្ជាក់របស់លោកមេឃុំគោកធ្លោកក្រោមលេខ ៩៦/២០០៤ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៤ ។

ទី៦ : ដីមួយកន្លែងស្ថិតនៅភូមិគីឡូតាឈឹម ឃុំគោកធ្លកក្រោម ស្រុកជីក្រែង ខេត្តសៀមរាប មានព្រំប្រទល់ខាងជើងទល់ឈ្មោះ ស ស ខាងត្បូងទល់ផ្លូវជាតិលេខ ៦អា ខាងកើតទល់ឈ្មោះ គ គ ខាងលិចទល់ឈ្មោះ ស ស មានលិខិតបញ្ជាក់របស់លោកមេឃុំគោកធ្លកក្រោម លេខ ៩៥/២០០៤ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៤ ។

ទី៧ : គោញីមួយក្បាល និង ទូបេង ០២គ្រឿង, គ្រែបេង ០១គ្រឿង, ខ្ទះសំរាប់អង្គុយបេង, តុបេង ០១, កៅអីបេង ០៩, ជង្រុកស្រូវមួយ, ផ្ទះបាយមួយ និង សំភារៈផ្សេងៗទៀត ស្ថិតនៅលើដីរបស់ក្មួយក្មេកនោះខ្លួនសុខចិត្តប្រគល់អោយឈ្មោះ ម ត គ្រប់គ្រងជាកម្មសិទ្ធិចុះ ។

ចំណែកឯដីមួយកន្លែងស្ថិតនៅផ្លូវទៅភ្នំបូក ស្ថិតនៅភូមិលលៃ ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប មានព្រំប្រទល់ខាងជើងទល់ឈ្មោះ ម ផ ខាងត្បូងទល់ឈ្មោះ អាន ខាងកើតទល់ស្ទឹង និង ខាងលិចទល់ផ្លូវមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៤ ដែលមានលេខ ៥១៨/២០០៤ ឃបគ ចុះនៅថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤ របស់លោកមេឃុំបាគង ជាទ្រព្យផ្ទាល់របស់ដើមចោទឈ្មោះ ម ត មានមុនបានខ្លួនជាប្ដីនោះ ខ្លួនសុខចិត្តប្រគល់អោយទៅដើមចោទឈ្មោះ ម ត គ្រប់គ្រងជាកម្មសិទ្ធិចុះ ខ្លួនមិនទាមទារឡើយ ។

ចំណែកឯបំណុលរួមមានឈ្មោះ ថាត ជំពាក់ស្រូវចំនួន ៤០ថាំង, ឈ្មោះ ន សខ ជំពាក់ប្រាក់ចំនួន ១០០ ដុល្លាអាមេរិក ខ្លួនសុខចិត្តចែកបំណុលនេះពាក់កណ្ដាលម្នាក់ស្មើគ្នា ។

ខ្លួនសុខចិត្តប្រគល់មាសចំនួន ០១ជី ០៥ហ៊ុន នៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៦ ជាចំណែកពាក់កណ្ដាលថ្លៃបញ្ចាំដីស្រែអោយទៅដើមចោទឈ្មោះ ម ត ដើម្បីបញ្ចប់រឿងក្ដីនេះ ។

ចំពោះដីទិញលក់ក្នុងក្រុមហ៊ុនមានគ្នា ០៩នាក់នោះ នៅពេលដោះស្រាយលក់ដីនេះបានប្រាក់ ខ្លួនយល់ព្រមចែកនូវចំណែកពាក់កណ្ដាលអោយទៅដើមចោទ ក្រោយពីចែកទៅអោយក្រុមហ៊ុនរួចរាល់ ។

## តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា

រឿងនេះជារឿងរដ្ឋប្បវេណី ដែលជាប្រភេទរឿងអាពាហ៍ពិពាហ៍ និង គ្រួសារ ដែលគោលបំណងអាពាហ៍ពិពាហ៍លែងបានសំរេច ដោយមានសភាពធ្ងន់ធ្ងរភាគីទាំងពីរពុំអាចរួមរស់នៅជាមួយគ្នាតទៅទៀតបានដើមចោទ និង ចុងចម្លើយអស់មនោសញ្ចេតនាពីគ្នាហើយ ។

ទោះបីមានការលែងលះគ្នាក៏ដោយ ភាគីទាំងពីរមិនទុកគ្នាជាសត្រូវ ហើយឪពុកម្ដាយត្រូវមានកាតព្វកិច្ចអប់រំ ចិញ្ចឹមកូន តាមច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។

ហេតុនេះសូមតុលាការពិចារណាសំរេចតាមច្បាប់ចុះ ។

CS CamScanner

-បានស្តាប់ចម្លើយដើមចោទឆ្លើយអោយការណ៍ និង ប្តឹងសុំ

-បានស្តាប់ចម្លើយចុងចម្លើយឆ្លើយដោះសារ និង ប្តឹងសុំ

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

**តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ**

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

-ពាក្យបណ្តឹងរបស់ដើមចោទ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៦ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

-គូស្វាមីភរិយានេះបានក្លាយជាប្តីប្រពន្ធមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។

-ដើមចោទប្តឹងសុំលែងលះចុងចម្លើយ មានមូលហេតុត្រឹមត្រូវតាមច្បាប់ ។

-ចំពោះកូន ០៣នាក់ គឺកូនទី១ ឈ្មោះ ស សធ ភេទប្រុស អាយុ ១០ឆ្នាំ, កូនទី២ ឈ្មោះ ស បធ ភេទប្រុស អាយុ ០៩ឆ្នាំ និង កូនទី៣ ឈ្មោះ ស បថ ភេទប្រុស អាយុ ០៧ឆ្នាំ ដើមចោទសុំសិទ្ធិគ្រប់គ្រង ហើយចុងចម្លើយក៏យល់ព្រមដែរនោះ តុលាការនឹងពិចារណាសំរេចទៅតាមការព្រមព្រៀងរបស់គូភាគី ។

-ដើមចោទប្តឹងទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូនផ្តាច់ចំនួន ១.០០០ដុល្លា ( មួយពាន់ដុល្លាអាមេរិក) ហើយចុងចម្លើយបានស្ម័គ្រចិត្តយល់ព្រមដែរនោះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-ទ្រព្យសម្បត្តិរួម :

ទី១ : ដីមួយកន្លែងស្ថិតនៅភូមិថ្នល់លោក ឃុំស្ពានត្នោត ស្រុកជីក្រែង ខេត្តសៀមរាប មានព្រំប្រទល់ ខាងជើងទល់ឈ្មោះ ខុធ ខាងត្បូងទល់ឈ្មោះ ហ៊ុត ខាងកើតទល់ឈ្មោះ ហ៊ុត និង ខាងលិចទល់ផ្លូវមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលមានលេខ ១១០ /២០០៥ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៥ របស់លោកមេឃុំស្ពានត្នោត ។

ទី២ : ដីមួយកន្លែងស្ថិតនៅភូមិត្រាច ឃុំបល្ល័ង្ក ស្រុកប្រាសាទបាគង ខេត្តសៀមរាប មានព្រំប្រទល់ ខាងជើងទល់ផ្លូវរទេះ ខាងត្បូងទល់ឈ្មោះ ម ម ខាងកើតទល់ផ្លូវលំ និង ខាងលិចទល់ឈ្មោះ ទ ត មានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤ ដែលមានលេខ ៧០៤ ឃបល ចុះនៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៤ របស់លោកមេឃុំបល្ល័ង្ក ។

ទី៣ : ម៉ូតូមួយគ្រឿងម៉ាក VIVA ពណ៌ក្រហម ស៊េរី ២០០៦ ហាងអ៊ុតសក់មួយកន្លែង ស្ថិតនៅភូមិទ្រាំង ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ជង្រុកស្រូវមួយស្ថិតនៅថ្នល់លោក ឃុំស្ពានត្នោត ស្រុកជីក្រែង ខេត្តសៀមរាប ខ្លួនសុំសិទ្ធិគ្រប់គ្រងជាកម្មសិទ្ធិ ។

ទី៤ : ដីមួយកន្លែងស្ថិតនៅភូមិចំរេះ ឃុំស្ពានត្នោត ស្រុកជីក្រែង ខេត្តសៀមរាប មានព្រំប្រទល់ ខាងជើង ទល់ផ្លូវជាតិលេខ ៦អា ខាងត្បូងទល់ផ្លូវលំ ខាងកើតទល់ឈ្មោះ ហ៊ុត និង ខាងលិចទល់ឈ្មោះ តៃ មានពាក្យស្នើ សុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៤ ដែលមានលេខ ៧៥/២០០៤ ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៤ របស់លោកមេឃុំបល្ល័ង្ក ។

ទី៥ : ដីមួយកន្លែងស្ថិតនៅភូមិគីឡូតាឈឹម ឃុំគោកធ្លកក្រោម ស្រុកជីក្រែង ខេត្តសៀមរាប

CamScanner

មានព្រំប្រទល់ខាងជើងទល់ឈ្មោះ ស ស ខាងត្បូងទល់ផ្លូវជាតិលេខ ៦អា ខាងកើតទល់ឈ្មោះ ស ច និង ខាងលិច ទល់ឈ្មោះ ស ច មានលិខិតបញ្ជាក់របស់លោកមេឃុំគោកធ្លកក្រោមលេខ ៩៦/២០០៤ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៤ ។

ទី៦ : ដីមួយកន្លែងស្ថិតនៅភូមិគីឡូតាឈឹម ឃុំគោកធ្លកក្រោម ស្រុកជីក្រែង ខេត្តសៀមរាប មានព្រំប្រទល់ខាងជើងទល់ឈ្មោះ ស ស ខាងត្បូងទល់ផ្លូវជាតិលេខ ៦អា ខាងកើតទល់ឈ្មោះ គ គ ខាងលិច ទល់ឈ្មោះ ស ស មានលិខិតបញ្ជាក់របស់លោកមេឃុំគោកធ្លកក្រោមលេខ ៩៥/២០០៤ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៤ ។

ទី៧ : គោញីមួយក្បាល និង ទូបេង ០២គ្រឿង, គ្រែរេង ០១គ្រឿង, ខ្ទះសំរាប់អង្គុយលេង ០១ តុបេង ០១, កៅអីបេង ០៩, ជង្រុកស្រូវមួយ, ផ្ទះបាយមួយ និង សំភារៈផ្សេងៗទៀតនៅលើដីរបស់ម្ដាយដើមចោទ នោះដើមចោទឈ្មោះ ម ត សុំសិទ្ធិគ្រប់គ្រងជាកម្មសិទ្ធិ ហើយចុងចម្លើយព្រមព្រៀងប្រគល់អោយដែរនោះមាន លក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-ចំណែកដីមួយកន្លែងស្ថិតនៅផ្លូវទៅភ្នំបូក ស្ថិតនៅភូមិលលៃ ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប មានព្រំប្រទល់ខាងជើងទល់ឈ្មោះ ម ផ ខាងត្បូងទល់ឈ្មោះ អាន ខាងកើតទល់ស្ទឹង និង ខាងលិច ទល់ផ្លូវ មានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៤ ដែលមានលេខ ៥១៨/២០០៤ ឃបគ ចុះនៅថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤ របស់លោកមេឃុំបាគងជាទ្រព្យផ្ទាល់ របស់ដើមចោទឈ្មោះ ម ត មានមុនបានចុងចម្លើយឈ្មោះ ម សធ ជាប្ដីនោះ ដើមចោទសុំសិទ្ធិគ្រប់ គ្រង ហើយចុងចម្លើយក៏បានព្រមព្រៀងប្រគល់អោយម្ចាស់កម្មសិទ្ធិវិញដែរនោះ មានលក្ខណៈត្រឹមត្រូវតាម ច្បាប់ ។

-បំណុលរួមមានឈ្មោះ ថវត ជំពាក់ស្រូវចំនួន ៤០ថាំង, ឈ្មោះ ន សខ ជំពាក់ប្រាក់ចំនួន ១០០ដុល្លា អាមេរិក ដើមចោទសុំបែងចែកបំណុលនេះពាក់កណ្ដាលម្នាក់ស្មើគ្នា ហើយចុងចម្លើយក៏ព្រមព្រៀងដែរ នោះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-ចុងចម្លើយសុខចិត្តប្រគល់មាសចំនួន ០១ជី០៥ហ៊ុន ជាចំណែកពាក់កណ្ដាលថ្លៃបញ្ចាំដីស្រែ អោយទៅ ដើមចោទ នៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៦ ហើយដើមចោទក៏ព្រមព្រៀងដែរនោះ មានលក្ខណៈ ត្រឹមត្រូវតាមច្បាប់ ។

-ដីទិញ-លក់ ក្នុងក្រុមហ៊ុនមានគ្នា ០៩នាក់ គឺមានឈ្មោះ ម ផ ០១, ឈ្មោះ ស ឡ ០១, ឈ្មោះ គ ត ០១, ឈ្មោះ ត ផ ០១, ឈ្មោះ ថ ផ ០១, ឈ្មោះ ឡ មហ ០១, ឈ្មោះ ថុន ០១ និង ចុងចម្លើយ ០១ ដែរនោះ នៅពេលដោះស្រាយលក់ដីនោះបានប្រាក់ហើយ ទូទាត់អោយទៅអ្នកមានភាគហ៊ុនរួចរាល់ ចុងចម្លើយយល់ព្រមចែកចំណែកពាក់កណ្ដាលឱ្យទៅដើមចោទតាមសំណូមពរ នោះតុលាការនឹងពិចារណា សំរេចទៅតាមការព្រមព្រៀងរបស់គូភាគី ។

-គោលដៅនៃអាពាហ៍ពិពាហ៍ពុំអាចសំរេចបានឡើយ ដោយដើមចោទអស់មនោសញ្ចេតនាពីចុងចម្លើយ ហើយ ។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្ដី

១-ទទួលពាក្យបណ្ដឹងរបស់ដើមចោទទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

CamScanner

២-សំរេចឱ្យអ្នកស្រី ម ត និង លោក ម សធ លែងលះគ្នាចាប់ពីថ្ងៃនេះតទៅ ។ ដាក់កំហុសលើប្តី ។

៣-សំរេចឱ្យអ្នកស្រី ម ត ស្ថិតនៅភាពមេម៉ាយចំនួន ៣០០ថ្ងៃ គិតចាប់ពីថ្ងៃនេះតទៅ ។

៤-កូន ០៣នាក់ គឺកូនទី១ ឈ្មោះ ស សធ ភេទប្រុស អាយុ ១០ ឆ្នាំ, កូនទី២ ឈ្មោះ ស មធ ភេទប្រុស អាយុ ០៩ឆ្នាំ និង កូនទី៣ ឈ្មោះ ស មថ ភេទប្រុស អាយុ ០៧ឆ្នាំ ត្រូវប្រគល់អោយដើមចោទគ្រប់គ្រងតាមការព្រមព្រៀងរបស់គូភាគី ។ តែអោយឈ្មោះ ម សធ បង់ប្រាក់ចិញ្ចឹមកូនផ្តាច់តែម្តងចំនួន ១.០០០ដុល្លា ( មួយពាន់ដុល្លាអាមេរិក) តាមការព្រមព្រៀង ។
មាតាបិតាត្រូវមានសិទ្ធិ និង ករណីកិច្ចអប់រំ ថែរក្សា ចិញ្ចឹមកូនតាមមាត្រា ៧៤ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។

៥-ទុកសិទ្ធិអោយចុងចម្លើយទៅសួរសុខទុក្ខដល់កូនបាន ។

៦-ទ្រព្យសម្បត្តិរួមមាន :

-ដីមួយកន្លែងស្ថិតនៅភូមិចំរេះ ឃុំស្ពានត្នោត ស្រុកជីក្រែង ខេត្តសៀមរាប មានព្រំប្រទល់ ខាងជើងទល់ផ្លូវជាតិលេខ ៦អា ខាងត្បូងទល់ផ្លូវលំ ខាងកើតទល់ឈ្មោះ ហ៊ុត និង ខាងលិចទល់ឈ្មោះ តែ មានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៤ ដែលមានលេខ ៧៥/២០០៤ ចុះនៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៤ របស់លោកមេឃុំបល្ល័ង្ក ។

-ដីមួយកន្លែងស្ថិតនៅភូមិគីឡូតាឈឹម ឃុំគោកធ្លកក្រោម ស្រុកជីក្រែង ខេត្តសៀមរាប មានព្រំប្រទល់ខាងជើងទល់ឈ្មោះ ច ខ, ខាងត្បូងទល់ផ្លូវជាតិលេខ ៦អា, ខាងកើតទល់ឈ្មោះ ស ច និង ខាងលិចទល់ឈ្មោះ ស ច មានលិខិតបញ្ជាក់របស់លោកមេឃុំគោកធ្លកក្រោមលេខ ៩៦/២០០៤ ចុះថ្ងៃ ទី ២៦ ខែ មីនា ឆ្នាំ ២០០៤ ។

-ដីមួយកន្លែងស្ថិតនៅភូមិគីឡូតាឈឹម ឃុំគោកធ្លកក្រោម ស្រុកជីក្រែង ខេត្តសៀមរាប មានព្រំប្រទល់ខាងជើងទល់ឈ្មោះ ស ស ខាងត្បូងទល់ផ្លូវជាតិលេខ ៦អា ខាងកើតទល់ឈ្មោះ គ គ និង ខាងលិចទល់ឈ្មោះ ស ស មានលិខិតបញ្ជាក់របស់លោកមេឃុំគោកធ្លកក្រោមលេខ ៩៥/២០០៤ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៤ ។

-គោញីមួយក្បាល និង ទូបេង ០២, គ្រែបេង ០១, ខ្ទះសំរាប់អង្គុយលេង, តុបេង ០១, កៅអីបេង ០៩, ជង្រុកស្រូវមួយ និង ផ្ទះបាយមួយ និង សំភារៈផ្សេងៗទៀតស្ថិតនៅលើដីរបស់ម្តាយដើមចោទត្រូវប្រគល់ទៅអោយឈ្មោះ ម ត គ្រប់គ្រងជាកម្មសិទ្ធិតាមការព្រមព្រៀងរបស់គូភាគី ។

-ដីមួយកន្លែងស្ថិតនៅភូមិថ្នល់លោក ឃុំស្ពានត្នោត ស្រុកជីក្រែង ខេត្តសៀមរាប មានព្រំប្រទល់ខាងជើងទល់ឈ្មោះ ហ៊ុត ខាងកើតទល់ឈ្មោះ ហ៊ុត និង ខាងលិចទល់ផ្លូវ មានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលមានលេខ ១១០/២០០៥ ចុះនៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៥ របស់លោកមេឃុំស្ពានត្នោត ។

-ដីមួយកន្លែងស្ថិតនៅភូមិត្រាច ឃុំបល្ល័ង្ក ស្រុកប្រាសាទបាគង ខេត្តសៀមរាប មានព្រំប្រទល់ខាងជើងទល់ផ្លូវរទេះ ខាងត្បូងទល់ឈ្មោះ ម ម ខាងកើតទល់ផ្លូវលំ និង ខាងលិចទល់ឈ្មោះ ខ ត មានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤ ដែលមានលេខ ៧០៤ ឃបល ចុះនៅ

CamScanner

ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៤ របស់លោកមេឃុំបល្ល័ង្គ ។

-ម៉ូតូមួយគ្រឿងម៉ាក VIVA ពណ៌ក្រហម ស៊េរី២០០៦, ហាងអ៊ុតសក់មួយកន្លែង ស្ថិតនៅ ភូមិទ្រាំង ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប, ជង្រុកស្រូវមួយ ស្ថិតនៅភូមិថ្នល់លោក ឃុំស្ពានត្នោត ស្រុកជីក្រែង ខេត្តសៀមរាប ត្រូវប្រគល់ទៅអោយឈ្មោះ ម សច គ្រប់គ្រងជាកម្មសិទ្ធិតាមការព្រមព្រៀងរបស់គូភាគី ។

-សំរេចប្រគល់ដីមួយកន្លែងស្ថិតនៅផ្លូវទៅភ្នំបូក ស្ថិតនៅក្នុងភូមិលលៃ ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប មានព្រំប្រទល់ខាងជើងទល់ឈ្មោះ ម ផ, ខាងត្បូងទល់ឈ្មោះ រវាន ខាងកើតទល់ស្ទឹង និង ខាងលិចទល់ផ្លូវ មានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៤ ដែលមានលេខ ៥១៨/២០០៤ ឃបគ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤ របស់លោកមេឃុំបាគង ជាទ្រព្យផ្ទាល់របស់ដើមចោទឈ្មោះ ម ត ត្រូវប្រគល់អោយទៅឈ្មោះ ម ត ជាម្ចាស់កម្មសិទ្ធិវិញ ។

៨-បំណុលរួមមានឈ្មោះ ថវត ជំពាក់ស្រូវចំនួន ៤០ថាំង, ឈ្មោះ ន សខ ជំពាក់ប្រាក់ចំនួន ១.០០០ដុល្លាអាមេរិក ត្រូវបែងចែកពាក់កណ្តាលម្នាក់ស្មើគ្នាតាមការព្រមព្រៀងរបស់គូភាគី ។

៩-សំរេចអោយឈ្មោះ ម សច ប្រគល់មាសចំនួន ០១ជី ៥ហ៊ុន ជាចំណែកពាក់កណ្តាលថ្លៃបញ្ចាំដីស្រែអោយទៅឈ្មោះ ម ត នៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៦ តាមការព្រមព្រៀងរបស់គូភាគី ។

១០-ដីលក់-ទិញ ក្នុងក្រុមហ៊ុនមានគ្នា ០៩នាក់ គឺមានឈ្មោះ ម ផ ០១, ឈ្មោះ ស ឡ ០១ ឈ្មោះ គ ត ០១, ឈ្មោះ ត ផ ០១, ឈ្មោះ ថ ផ ០១, ឈ្មោះ ឡ បហ ០១, ឈ្មោះ ថុន ០១ និង ឈ្មោះ ម សច ០១ នៅពេលលក់ដីបានប្រាក់ ហើយទូទាត់អោយអ្នកមានភាគហ៊ុនរួចរាល់ នៅសល់ប្រាក់ប៉ុន្មានត្រូវអោយដើមចោទ និង ចុងចម្លើយ ចែកចំណែកពាក់កណ្តាលម្នាក់ស្មើគ្នាតាមការព្រមព្រៀងរបស់គូភាគី ។

១១-សំរេចឱ្យចុងចម្លើយឈ្មោះ ម សច បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹង ១.៨០០រ០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រ០០ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រ០០ បូករួម ៧.០០០រ០០ ។ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០រ០០ នេះទៅដើមចោទវិញ ។

១២-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់ ០២ខែ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

ក្រឡាបញ្ជីសវនាការ
ហត្ថលេខា និង ត្រា
[redacted]

ចៅក្រមជំនុំជំរះ
ហត្ថលេខា និង ត្រា
[redacted]

CamScanner